Mlup Baitong PO Box 2510, Phnom Penh 3, Cambodia

Tel: +855-10-413-857, +855-12-413 857, Website: www.mlup-baitong.org, E-mail: mlup@online.com.kh

# សេចក្តីជូនដំណឹង

# ស្តីពី

# ការជ្រើសរើសក្រុមហ៊ុន ឬនីតិ/រូបវ័ន្តបុគ្គលវាយតម្លៃបញ្ចប់គម្រោង នៃការអនុវត្តគម្រោង

# ការទទួលបានថាមពលសម្រាប់ប្រើប្រាស់តាមផ្ទះ និងអភិវឌ្ឍន៍អេកូទេសចរណ៍ ជាមួយនឹងការអភិរក្សព្រៃ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ របស់សហគមន៍ជនជាតិដើមភាគតិចស្ទួយ

សហគមន៍តំបន់ការពារធម្មជាតិរាំងខ្វាវស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៅក្នុងឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៤ និងមានការទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងបរិស្ថានលើលិខិតស្នើសុំរបស់សហគមន៍ (លេខ ២៦៤ស.ណ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥)។ សហគមន៍នេះចូលរួមគ្រប់គ្រងដោយប្រជាសហគមន៍ ភូមិរាំងខ្វាវ ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ មានផ្ទៃដីទំហំ ៧៧៦ហិកតា មានសមាជិកចូលរួមចំនួន ១៧៥គ្រួសារ ស្មើនឹង ៨៨២នាក់ (ស្រី ៣៩៤នាក់)។ រាំងខ្វាវជាសហគមន៍មានជនជាតិដើមភាគតិចស្ទួយចំនួន ២០គ្រួសារ (ប្រមាណជា ១០០នាក់) ដែលកំពុងព្យាយាមការពារអត្តសញ្ញាណជនជាតិដើមភាគតិចរបស់ខ្លួន ដូចជា របាំងប្រពៃណី បុណ្យសែនអារក្សបុណ្យសែនអ្នកតា និង មានតំបន់សក្តិសិទ្ធដែលពួកគាត់មានជំនឿ។ សហគមនទទួលបានការគាំទ្រមូលនិធីពី GEF-SGP-UNDP ប្រចាំប្រទេសកម្ពុជាក្រោមការជួយសម្របសម្រួលរបស់អង្គការម្លប់បៃតង បាននិងកំពុងអនុវត្តគម្រោង "**ការទទួលបានថាមពលសម្រាប់ប្រើប្រាស់តាមផ្ទះ និងអភិវឌ្ឍន៍អេកូទេសចរណ៍ ជាមួយនឹងការអភិរក្សព្រៃ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិចស្ទួយ**" គម្រោងលេខ KHM/SGP/OP6/Y6/CORE/IPAE/2020/04 រយៈពេល ១៨ខែ (ចាប់ពីថ្ងៃទី**១៦ ខែធ្នូ ឆ្នាំ២០២០** ដល់ ថ្ងៃទី**១៥ ខែមិថុនា ឆ្នាំ២០២២**)។ គម្រោងនេះ អនុវត្តនៅសហគមន៍តំបន់ការពារធម្មជាតិរាំងខ្វាវ ស្ថិតនៅក្នុងភូមិរាំងខ្វាវ ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ គម្រោងបានអនុវត្តបាន ១៧ខែ កន្លងមកហើយ និងបញ្ចប់នៅក្នុងខែមិថុនា ឆ្នាំ២០២២ ខាងមុខនេះ។ ចំពោះមុខគម្រោងសូមប្រកាសធ្វើការជ្រើសរើសក្រុមហ៊ុន ឬនីតិ/រូបវ័ន្តបុគ្គល ក្នុងការ**វាយតម្លៃបញ្ចប់គម្រោង** ក្នុងគោលបំណងដើម្បី ស្វែងរកពី*ប្រសិទ្ធភាព ប្រសិទ្ធផល ភាពពាក់ព័ន្ធ ផលប៉ះពាល់* និង***និរន្តរភាព***នៃគម្រោង ព្រមទាំងបទពិសោធន៍ដែលបានអនុវត្តកន្លងមក និងអនុសាសន៍នានាសម្រាប់រៀបចំផែនការអនុវត្តនាពេលអនាគតផងដែរ។

អាស្រ័យហេតុនេះ សូមក្រុមហ៊ុន ឬនីតិ/រូបវ័ន្តបុគ្គលមានបទពិសោធន៍ខាង**វាយតម្លៃបញ្ចប់គម្រោង** ដែលមានចំណាប់អារម្មណ៍ក្នុងការផ្តល់សេវានេះ សូមផ្ញើលិខិតចំណាប់អារម្មណ៍ ប្រវត្តិរូបសង្ខេប គម្រោងសង្ខេបរួមទាំងតម្លៃនៃការ**វាយតម្លៃបញ្ចប់គម្រោង** (គិតរួមទាំងថ្លៃពន្ធកាត់ទុក ១៥%) មកការិយាល័យ**អង្គការម្លប់បៃតង**តាមអាសយដ្ឋាន ផ្ទះលេខ១៩៤ ផ្លូវលេខ៣៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឬតាមរយៈអ៊ីម៉ែល mlup@online.com.kh; financemlup@online.com.kh, pcscfmmlup@gmail.com អោយបានមុនម៉ោង ៥ល្ងាចថ្ងៃ**ទី៣០** ខែ**ឧសភា** **ឆ្នាំ** **២០២២**។ *សូមពិនិត្យមើលនូវតួនាទី និងការទទួលខុសត្រូវ ដូចមានឯកសារជូនភ្ជាប់មកជាមួយ។*

ព័ត៌មានបន្ថែម សូមទាក់ទងក្រុមការងារម្លប់បៃតង តាមរយៈទូរស័ព្ទលេខ 010-413-857, 012-413-857, 078-555-209, 087-840-136 រៀងរាល់ម៉ោងធ្វើការ។

Mlup Baitong PO Box 2510, Phnom Penh 3, Cambodia

Tel: +855-12-413-857, +855-10-413 857, Website: www.mlup-baitong.org, E-mail: mlup@online.com.kh

# ជ្រើសរើសក្រុមហ៊ុន ឬនីតិ/រូបវ័ន្តបុគ្គល វាយតម្លៃបញ្ចប់គម្រោងនៃការអនុវត្តគម្រោង ការទទួលបានថាមពលសម្រាប់ប្រើប្រាស់តាមផ្ទះ និងអភិវឌ្ឍន៍អេកូទេសចរណ៍ ជាមួយនឹងការអភិរក្សព្រៃ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ របស់សហគមន៍ជនជាតិដើមភាគតិចស្ទួយ

| | | |
|---|---|---|
| ផ្តល់មូលនិធិដោយ | ៖ | GEF SGP UNDP ប្រចាំប្រទេសកម្ពុជា |
| **ទីតាំងគម្រោង** | ៖ | ភូមិរាំងខ្នារ ឃុំសន្រ្ទែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ |
| រយៈពេលអនុវត្តគម្រោង | ៖ | ១៨ខែ (ថ្ងៃទី**១៦ ខែ ធ្នូ ឆ្នាំ ២០២០** ដល់ ថ្ងៃទី**១៥ ខែ មិថុនា ឆ្នាំ ២០២២**) |
| **អនុវត្តគម្រោងដោយ** | **៖** | **សហគមន៍តំបន់ការពារធម្មជាតិរាំងខ្នារ** |
| សម្របសម្រួលដោយ | ៖ | អង្គការម្លប់បៃតង |

## ១. ប្រវត្តសហគមន៍

សហគមន៍តំបន់ការពារធម្មជាតិរាំងខ្នារស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ នៅក្នុងឃុំសន្រ្ទែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៤ និងមានការទទួលស្គាល់ពីរដ្ឋមន្រ្តីក្រសួងបរិស្ថានលើលិខិតស្នើសុំរបស់សហគមន៍ (លេខ ២៦៤ស.ណ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥)។ សហគមន៍នេះចូលរួមគ្រប់គ្រងដោយប្រជាសហគមន៍ ភូមិរាំងខ្នារ ឃុំសន្រ្ទែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ មានផ្ទៃដីទំហំ ៧៧៦ហិកតា មានសមាជិកចូលរួមចំនួន ១៧៥គ្រួសារ ស្មើនឹង ៨៨២នាក់ (ស្រី ៣៩៨នាក់)។ រាំងខ្នារជាសហគមន៍មានជនជាតិដើមភាគតិចស្ទួយចំនួន ២០គ្រួសារ (ប្រមាណជា ១០០ នាក់) ដែលកំពុងព្យាយាមការពារអត្តសញ្ញាណជនជាតិដើមភាគតិចរបស់ខ្លួន ដូចជា របាំងប្រពៃណី បុណ្យសែនអារក្ស បុណ្យសែនអ្នកតា និង មានតំបន់សក្តិសិទ្ធដែលពួកគាត់មានជំនឿ។ ក្នុងឆ្នាំ២០២០ សហគមន៍តំបន់ការពារធម្មជាតិរាំងខ្នារបានទទួលមូលធិនិគ្រាំទ្រពី GEF SGP UNDP ប្រចាំប្រទេសកម្ពុជា ក្រោមការជួយសម្របសម្រួលពីអង្គការម្លប់បៃតងក្នុងការអនុវត្តគម្រោង "**ការទទួលបានថាមពលសម្រាប់ប្រើប្រាស់តាមផ្ទះ និងអភិវឌ្ឍន៍អេកូទេសចរណ៍ ជាមួយនឹងការអភិរក្សព្រៃ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិចស្ទួយ**"។

## ២. បរិយាយគម្រោង

គោលដៅគម្រោង៖ សហគមន៍ជនជាតិដើមភាគតិចស្ទួយ និងសមាជិកសហគមន៍មានភ្លើងប្រើប្រាស់ និងធ្វើយ៉ាងណាឱ្យផ្ទៃដីព្រៃរបស់សហគមន៍តំបន់ការពារធម្មជាតិរាំងខ្នារ ដែលមានទំហំ ៧៧៦ហិកតា ត្រូវបានការពារ ប្រើប្រាស់ និងគ្រប់គ្រងប្រកបដោយនិរន្តរភាព ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍ឱ្យកាន់តែល្អប្រសើរ។

គោលបំណង១៖ សហគមន៍ជនជាតិដើមភាគតិចស្ទួយ និងសមាជិកសហគមន៍ចំនួន ១៧៥គ្រួសារ ដែលមានប្រជាជនសរុបចំនួន ៨៨២នាក់ (ស្រី ៣៩៤នាក់) ក្នុងតំបន់គោលដៅ ចូលរួមអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍នៅសហគមន៍តំបន់ការពារធម្មជាតិរាំងខ្វារ ដែលមានផ្ទៃដីព្រៃ ៧៧៦ហិចតា ប្រកបដោយនិរន្តរភាពនៅឆ្នាំ២០២២។

គោលបំណង២៖ ជនជាតិដើមភាគតិចស្ទួយ និងសមាជិកសមាជិកសហគមន៍យ៉ាងតិចចំនួន ១៧៥គ្រួសារ ក្នុងសហគមន៍គោលដៅមានភ្លើងប្រើប្រាស់ តាមរយៈការបង្កើតស្ថានីយអគ្គីសនីសូឡាសហគមន៍ (បញ្ចូលអាគុយ និងប្រើប្រាស់ឋាមពលអគ្គីសនីសម្រាប់មណ្ឌលព័ត៌មានទេសចរណ៍) ការបង្កើតស្ថានីយផលិតទឹកស្អាតសហគមន៍ និងអភិវឌ្ឍសេវាកម្មសហគមន៍អេកូទេសចរណ៍ ដែលធ្វើឲ្យពួកគាត់មានជីវភាពកាន់តែល្អប្រសើរនៅឆ្នាំ២០២២។

អ្នកទទួលផល៖ សហគមន៍ជនជាតិដើមភាគតិចស្ទួយ និងសមាជិកសហគមន៍ចំនួន ១៧៥គ្រួសារ ដែលមានប្រជាជនសរុបចំនួន ៨៨២នាក់ (ស្រី ៣៩៤នាក់) ក្នុងតំបន់គោលដៅ។

## ៣. គោលបំណងនៃការវាយតម្លៃ

គោលបំណងនៃការ**វាយតម្លៃបញ្ចប់គម្រោង**នេះ គឺដើម្បីស្វែងរកពី*ប្រសិទ្ធភាព ប្រសិទ្ធផល ភាពពាក់ព័ន្ធ ផលប៉ះពាល់* និង*និរន្តរភាព*នៃគម្រោង ព្រមទាំងបទពិសោធន៍ដែលបានអនុវត្តកន្លងមក និងអនុសាសន៍នានាសម្រាប់រៀបចំផែនការអនុវត្តនាពេលអនាគតផងដែរ។

## ៤. ព័ត៌មានការស្នើសុំដាក់ពាក្យ

- មុខងារ ៖ អ្នកវាយតម្លៃបញ្ចប់គម្រោង
- ប្រភេទការងារ ៖ កិច្ចសន្យារយៈពេលខ្លី
- ពេលវេលា ៖ ចាប់ពីថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២២
- ផលិតផលរង្វាយតម្លៃ ៖ ប្រគល់-ទទួលរបាយការណ៍បញ្ចប់ យ៉ាងយូរត្រឹមថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២
- ប្រាក់កម្រៃ ៖ ចរចារ (គិតរួមទាំងពន្ធកាត់ទុក ១៥%)

## ៥. លក្ខណៈសម្បត្ត

ដើម្បីទទួលបានលទ្ធផលវាយតម្លៃដោយសុក្រឹតភាព និងអាចទទួលយកបាន ក្រុមហ៊ុន/នីតិបុគ្គល ឬ រូបវ័នបុគ្គល ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- បរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ ដែលមានមុខវិជ្ជាពាក់ព័ន្ធ។
- មានបទពិសោធន៍ការងារជាមួយ NGO
- មានបទពិសោធន៍ការងារវាយតម្លៃគម្រោងអភិវឌ្ឍន៍

## ៦. វិសាលភាពការងារ

- វាយតម្លៃប្រសិទ្ធភាព ប្រសិទ្ធផល ភាពពាក់ព័ន្ធ ផលប៉ះពាល់ និងនិរន្តរភាពនៃគម្រោង។

- វាយតម្លៃ និងបង្ហាញពីបទពិសោធន៍ (lesson learned) ដែលគម្រោងបានអនុវត្ត និងអនុសាសន៍សម្រាប់រៀបចំផែនការអនុវត្តនាពេលអនាគត។
- ការវាយតម្លៃត្រូវ**គ្របដណ្តប់គ្រប់តំបន់គោលដៅនៃគម្រោង ដូចមានបញ្ជាក់នៅក្នុងផ្នែកទីតាំងគម្រោង**។
- ទំហំនៃការជ្រើសរើសគំរូ (sample) យ៉ាងតិច **២០%នៃគ្រួសារទទួលផល** និង ៤០% ទៅ ៥០%នៃអ្នកពាក់ព័ន្ធក្នុងសម្របសម្រួល និងការគ្រប់គ្រងគម្រោង។

## ៧. តួនាទីនិងការទទួលខុសត្រូវរបស់អ្នកវាយតម្លៃ

ផ្អែកលើការជ្រើសរើសដោយ**អង្គការម្លប់បៃតង** បេក្ខជនដែលបានមានបំណងដាក់ពាក្យសម្រាប់ការវាយតម្លៃគម្រោងនេះ ត្រូវផ្តល់ជូនមក**អង្គការម្លប់បៃតង**នូវ៖

- ផែនការសកម្មភាពលំអិត
- វិធីសាស្ត្រវាយតម្លៃរួមមាន៖ ប្រភេទទិន្នន័យ វិធីសាស្រ្ត និងឧបករណ៍ប្រមូលទិន្នន័យ និងរបៀប/វិធីសាស្ត្រវិភាគទិន្នន័យ និងព័ត៌មាន។
- ពិគ្រោះយោបល់ជាមួយ**អង្គការម្លប់បៃតង**អំពី ទម្រង់របាយការណ៍ កម្រងសំនួរ និងកិច្ចពាក់ព័ន្ធផ្សេងៗ មុននឹងចុះប្រមូលទិន្នន័យ។
- សេចក្តីព្រាងរបាយការណ៍ធ្វើឡើងជាភាសាខ្មែរ ព័ត៌មានត្រឹមត្រូវ និងមិនលំអៀង។
- ធ្វើបទបង្ហាញសេចក្តីព្រាងរបាយការណ៍ទៅ**អង្គការម្លប់បៃតង** ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផលវាយតម្លៃ និងឈានទៅបញ្ចប់ របាយការណ៍វាយតម្លៃគម្រោងស្ថាពរ។

## ៨. ការដាក់ពាក្យ និងកាលបរិច្ឆេទផុតកំណត់ទទួលពាក្យ

ក្រុមហ៊ុន/នីតិ/រូបវន្តបុគ្គល ដែលមានបទពិសោធន៍ និងមានចំណាប់អារម្មណ៍ សូមផ្ញើនូវប្រវត្តិរូបសង្ខេប ផែនការសកម្មភាពលំអិតរួមទាំងតម្លៃ និងពន្ធកាត់ទុកលើសេវាកម្ម(១៥%) មកកាន់ការិយាល័យ**អង្គការម្លប់បៃតង** តាមអាសយដ្ឋានផ្ទះលេខ១៦៤ ផ្លូវលេខ៣៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឬតាមរយៈអ៊ីម៉ែល៖ financemlup@online.com.kh; pcscfmmlup@gmail.com; mlup@online.com.kh ឲ្យបានមុនម៉ោង ៥ល្ងាច ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២។

ព័ត៌មានបន្ថែម សូមទាក់ទងក្រុមការងារម្លប់បៃតង តាមរយៈទូរស័ព្ទលេខ 010-413-857, 012-413-857, 078-555-209, 087-840-136 រៀងរាល់ម៉ោងធ្វើការ។

*********